**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ២៩ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា ៦ មាត្រា ៩ និងមាត្រា ១២ នៃអនុក្រឹត្យលេខ ០៧អនក្រ.បក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា

* * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស /រកម /០៨០៦/២២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ២ និង មាត្រា ១៥ ស្តីពីច្បាប់សភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម

- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

### មាត្រា មួយ ..

មាត្រា ៦ មាត្រា ៩ និង មាត្រា ១២ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា ត្រូវបានកែសម្រួលដូចខាងក្រោម ÷

### មាត្រា ៦ ថ្មី ..

សមាជិកសភាពាណិជ្ជកម្មកម្ពុជា មានអាណត្តិ ៣ (បី) ឆ្នាំ ហើយត្រូវជ្រើសតាំងសារជាថ្មី នៅក្រោយពេលបោះឆ្នោត ជ្រើសតាំងសភាពាណិជ្ជកម្មរាជធានី ខេត្ត នីមួយៗ រាល់ ៣ (បី) ឆ្នាំម្តង ។

សមាជិកសភាពាណិជ្ជកម្មកម្ពុជា ត្រូវជ្រើសតាំងបង្គ្រប់នៅពេលមានកន្លែងទំនេរ ស្របតាមមាត្រា៥ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា ។

### មាត្រា ៩ ថ្មី ..

សភាពាណិជ្ជកម្មកម្ពុជា ត្រូវគ្រប់គ្រងដោយការិយាល័យប្រតិបត្តិ ដែលមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| - ប្រធានសភាពាណិជ្ជកម្មកម្ពុជា | ជាប្រធាន |
| - ប្រធានសភាពាណិជ្ជកម្មរាជធានី ខេត្ត ទាំងអស់ | ជាអនុប្រធាន |
| - សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្មរាជធានី ខេត្ត មួយចំនួន | ជាអនុប្រធាន |
| - សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្មរាជធានី ខេត្ត មួយរូប | ជាហេរញ្ញិក |
| - សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្មរាជធានី ខេត្ត មួយរូប | ជាលេខាធិការ ។ |

### មាត្រា ១២ ថ្មី ..

ប្រធានសភាពាណិជ្ជកម្មរាជធានី ខេត្តទាំងអស់ប្រជុំគ្នា ធ្វើការបោះឆ្នោតជ្រើសតាំងសមាសភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្មកម្ពុជា ។ ការបោះឆ្នោតត្រូវរៀបចំដោយគណៈកម្មការមួយ ដែលមានសមាជិក ២រូប ÷

- ប្រធាន ជ្រើសរើសយកសមាជិកដែលមានអាយុច្រើនជាងគេ
- សមាជិក និងជាលេខាធិការ ជ្រើសរើសយកសមាជិកដែលមានអាយុតិចជាងគេ ។

ការបោះឆ្នោតត្រូវមានតំណាងក្រសួងពាណិជ្ជកម្ម ចូលរួម ។

សមាសភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្មកម្ពុជា ត្រូវទទួលស្គាល់ដោយអនុក្រឹត្យ ។

**មាត្រា ពីរ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា បី ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានសភាពាណិជ្ជកម្មកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ដើម្បីសូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា បី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ